## មហាវិទ្យាល័យស្ថាបត្យកម្ម និងសំណង់ស៊ីវិល
**(Faculty of Architecture and Civil Engineering)**

### ជំនាញស្ថាបត្យកម្ម (Department of Architecture)

### ១. គោលបំណងនៃកម្មវិធីសិក្សា (Program Aims)

កម្មវិធីអប់រំបរិញ្ញាបត្រស្ថាបត្យកម្ម ជំនាញស្ថាបត្យកម្ម ត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱ្យនិស្សិតនូវចំណេះ ដឹងមូលដ្ឋានស្ថាបត្យកម្ម តាមបទដ្ឋាននៃការគូសប្លង់អគារតូចធំ តាមរចនាបទខ្មែរ ឬអឺរ៉ុបបែបបុរាណ និងសម័យ ដោយឈរលើគោលការណ៍ណ៍ស្តង់ដាបរិស្ថានស្អាត។

កម្មវិធីអប់រំនេះនឹងផ្តល់ឱ្យនិស្សិតផងដែរនូវបទពិសោធន៍ បច្ចេកទេសល្អៗ និងសមត្ថភាពគ្រប់គ្រងគម្រោង ជាមួយនិងការពិចារណាបែបស៊ីជម្រៅសម្រាប់ការផ្តល់ដំណោះ ស្រាយដ៏សមរម្យ។ ទន្ទឹមនឹងចំណេះដឹងនិងជំនាញនិស្សិតក៏ត្រូវសិក្សា ផងដែរមូលដ្ឋាននៃការវិភាគ ក្រមសិលធម៌ បទបញ្ញត្តិសុវត្ថិភាព និងទំនាក់ទំនងដើម្បីអាចចូលរួមការងារជាក្រុម ក៏ដូចការងារបុគ្គលរៀងៗខ្លួន ប្រកបដោយ ការទទួលខុសត្រូវ។ មិនតែប៉ុណ្ណោះ និស្សិតនឹងទទួលបានពីកម្មវិធីនេះនូវសមត្ថភាពស្វ័យសិក្សានិងស្រាវជ្រាវ ដែលជាមូលដ្ឋានក្នុងការសិក្សាបន្តដើម្បីទទួលគុណវុឌ្ឍកម្រិតខ្ពស់បន្តទៀត។

ក្រោយពីបានបញ្ចប់ការសិក្សានិស្សិតនឹងទទួលបានចំណេះដឹង និងជំនាញជាក់លាក់ដែលនឹងជួយឱ្យ ពួកគេសម្រេចបានជោគជ័យទាំងក្នុងអាជីពការងារ និងអាជីវកម្មក្នុងពេលអនាគត។

### ២.ឱកាសការងារ

ក្រោយពីទទួលបានបរិញ្ញាបត្រ ជំនាញស្ថាបត្យកម្ម និស្សិតបញ្ចប់ការសិក្សា អាចទទួលបាននូវឱកាសការងារ ដូចខាងក្រោម៖

- ស្ថាបត្យកររចនានិងគូសប្លង់គ្រប់ប្រភេទអគារ
- ស្ថាបត្យករគ្រប់គ្រងគម្រោងស្ថាបត្យកម្ម
- ស្ថាបត្យករបច្ចេកទេសស្ថាបត្យកម្មនៅការដ្ឋានសំណង់
- ស្ថាបត្យករគ្រប់គ្រងការដ្ឋានសំណង់
- ស្ថាបត្យករផ្តល់ប្រឹក្សាបច្ចេកទេសស្ថាបត្យកម្ម
- ស្ថាបត្យករស្រាវជ្រាវ និងអភិវឌ្ឍស្ថាបត្យកម្ម
- ស្ថាបត្យករម៉ៅការសាងសង់សំណង់ផ្សេងៗ។

**ជំនាញសំណង់ស៊ីវិល (Civil Engineering)**

១. គោលបំណងនៃកម្មវិធីសិក្សា **(Program Aims)**

កម្មវិធីអប់រំបរិញ្ញាបត្រវិទ្យាសាស្ត្រ មុខជំនាញសំណង់ស៊ីវិល ត្រូវបានរៀបចំឡើង ដើម្បីផ្តល់អ្នកសិក្សានូវចំណេះដឹងមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រពិតនៃបច្ចេកទេសវិស្វកម្ម ក្នុងការវិភាគ គណនា និងគូសប្លង់វិស្វកឬដោយ ផ្តោតរួម ទៅលើការសាងសង់អគារ ប្រកបដោយការការពារបរិស្ថានបណ្តុត្រឹមត្រូវ។ ទន្ទឹមនេះ និស្សិតនឹងក្លាយជា វិស្វករដែលប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈល្អ ហើយអាចបំពេញការងារជាមួយអ្នកបច្ចេកទេសគ្រប់កម្រិត។

២. ឱកាសការងារ

ក្រោយពីទទួលបាន បរិញ្ញាបត្រវិស្វកម្ម ជំនាញវិស្វកម្មសំណង់ស៊ីវិល និស្សិតបញ្ចប់ការសិក្សាអាច បាននូវឱកាសការងារ ដូចខាងក្រោម៖

- វិស្វករសាងសង់សំណង់គ្រប់ប្រភេទ
- វិស្វករគូសប្លង់ដោយ Niko CAD
- វិស្វករក្នុងការិយាល័យ ឬការដ្ឋានសំណង់
- វិស្វករទេសគ្រប់គ្រងការដ្ឋានសំណង់
- វិស្វករគ្រប់គ្រងគម្រោងសំណង់វិស្វកម្ម
- វិស្វករពិគ្រោះយោបល់លើគម្រោងវិស្វកម្មសំណង់។

**មុខជំនាញវិស្វកម្មអគ្គិសនី និងអេឡិចត្រូនិច** (Electrical and Electronic Engineering)

១. គោលបំណងនៃកម្មវិធីសិក្សា (Program Aims)

**កម្មវិធីបរិញ្ញាបត្រវិស្វកម្មអគ្គិសនី វិស័យអេឡិចត្រូនិច** ផ្តល់ជូននូវសមត្ថភាពដើម្បីបំពេញការងារបច្ចុប្បន្ន និងអនាគតក្នុងវិស័យអេឡិចត្រូនិច និងស្វ័យប្រវត្តិកម្ម ផ្តល់ជំនាញគិតរិះគន់ដើម្បីអភិវឌ្ឍឧបករណ៍អេឡិចត្រូនិចថ្មីដោយផ្អែកលើការងារស្រាវជ្រាវសម្រាប់តម្រូវការបច្ចុប្បន្ននៃឧស្សាហកម្ម4.0 ។ ផ្តល់ជំនាញវិភាគផ្នែកអេឡិចត្រូនិច និងស្វ័យប្រវត្តិកម្មសម្រាប់ឧស្សាហកម្ម។ ផ្តល់ជំនាញរចនាគម្រោង រួមទាំងសមត្ថភាពពេញលេញក្នុងភាពជាអ្នកដឹកនាំ និងការងារជាក្រុម។ ផ្តល់ជំនាញ psychomotor សាកល្បងឧបករណ៍អេឡិចត្រូនិច និងកម្មវិធីបណ្តុះបណ្តាល។

២. ឱកាសការងារ

ក្រោយពីទទួលបាន បរិញ្ញាបត្រ ជំនាញវិស្វកម្មអគ្គិសនី និងអេឡិចត្រូនិច និស្សិតបញ្ចប់ការសិក្សា អាចទទួលបាននូវឱកាសការងារ ដូចខាងក្រោម៖

- វិស្វករដែលមានសមត្ថភាពពេញលេញក្នុងវិស័យអេឡិចត្រូនិច និងស្វ័យប្រវត្តិកម្មដើម្បបំពេញតម្រូវការទីផ្សារបច្ចុប្បន្ន និងអនាគតជាតិ និងអន្តរជាតិ

- វិស្វករវៀបចំប្រព័ន្ធអគ្គីសនីសម្រាប់ការិយាល័យ ឬការដ្ឋានសំណង់ ។